# តារាងពណ៌នាការងារមុខតំណែង

| | |
|---|---|
| មុខតំណែង: | ប្រធានក្រុមឥណទាន |
| នាយកដ្ឋាន: | នាយកដ្ឋានលក់ឥណទាន |
| រាយការណ៍ជូន: | ប្រធានសាខា |

## I. តួនាទី និងភារកិច្ច

- ត្រួតពិនិត្យវាយតម្លៃ កម្ចីដល់ទីតាំងអតិថិជន(ទីកន្លែងធ្វើជំនួញ) និងការបំពេញឯកសារកម្ចី ដែលធ្វើដោយមន្ត្រីឥណទាន។
- ត្រួតពិនិត្យនិងគ្រប់គ្រងដំណើរការនិងនិតិវិធីនៃការផ្តល់កម្ចី ប្រមូលកម្ចី និងការដោះស្រាយកម្ចីរបស់មន្ត្រីឥណទាន។
- ត្រួតពិនិត្យនិងធ្វើផែនការដាក់កម្ចី(លក់) ប្រចាំឆ្នាំ ប្រចាំខែ សប្តាហ៍ របស់មន្ត្រីឥណទាន។
- សិក្សា វាយតំលៃ ប្រមូលពត៌មាន នៃតំបន់ប្រតិបត្តិការសក្កានុពលនិងតំបន់គោលដៅ (ភូមិ/ឃុំ)៖ ឥរិយាបទអតិថិជន មុខរបរ ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពប្រវត្តិឥណទាន ស្ថានភាពដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ យុទ្ធសាស្ត្រនិងផលិតផលរបស់គូប្រកួតប្រជែង។
- គ្រប់គ្រងគុណភាពផលប័ត្រកម្ចី និងចូលរួមដោះស្រាយកម្ចីយឺតយ៉ាវឬស្ថិតក្នុងហានិភ័យឲ្យបានទាន់ពេលនិងរាយការណ៍ជូននាយកសាខា។
- ថែរក្សាអតិថិជន ចំណែកទីផ្សារនិងសេវាកម្មល្អ តាមរយៈការដោះស្រាយបណ្តឹងអតិថិជនឲ្យទាន់ពេល ស្វែងយល់ពីមូលហេតុពីអតិថិជន និងទំនាក់ទំនងល្អជាមួយអ្នកដែលពាក់ពន្ធ័។
- ផ្តល់ការបណ្តុះបណ្តាលជាប្រចាំពីគោលការណ៍ឥណទានដល់បុគ្គលិកដែលគ្រប់គ្រង និងគ្រប់គ្រង តាមដាន ជំរុញ និងគាំទ្រការអនុវត្តន៍ការងារបុគ្គលិក។
- ធ្វើរបាយការណ៍ជូននាយកសាខានូវលទ្ធផលការងារ និង បញ្ហានានា។

## II. លក្ខណៈសម្បត្តការងារតម្រូវ

- មានកម្រិតបរិញ្ញាប័ត្រជំនាញ ធនាគារ និងហិរញ្ញវត្ថុ គ្រប់គ្រងទូទៅ ឬសញ្ញាប័ត្រពាណិជ្ជកម្មមានលក្ខណៈប្រហាក់ប្រហែល។
- មានបទពិសោធន៍ក្នុងការផ្តល់ឥណទានយ៉ាងតិច២ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ឬធនាគារ។
- មានចំណេះដឹង ក្នុងការគ្រប់គ្រង និងដឹកនាំ។
- មានជំនាញដោះស្រាយបញ្ហា ការគិតទុកជាមុន និងមានគំនិតផ្តួចផ្តើម។
- ទំនាក់ទំនងល្អ រួសរាយរាក់ទាក់ ស្មោះត្រង់ និងមានការទទួលខុសត្រូវខ្ពស់។
- មានឆន្ទៈទៅបម្រើការងារនៅតាមខេត្ត ឬតំបន់ទីជនបទ។